# ឯកសារសង្ខេបអំពីដៃគូអនុវត្តជាយុទ្ធសាស្ត្រ
# ផ្នែក ការស្តារលទ្ធភាពពលកម្ម

## សង្ខេបគម្រោង

គោលដៅ៖ នៅឆ្នាំ២០២៨ មន្ទីរពេទ្យខេត្តកំពង់ចាមនឹងមានសមត្ថភាពកាន់តែប្រសើរឡើងក្នុងការផ្តល់សេវាស្តារលទ្ធភាពពលកម្ម ប្រកបដោយគុណភាព និងបរិយាបន្ន សម្រាប់អ្នកដែលមានបញ្ហាផ្នែកណាមួយនៃរាងកាយ រួមទាំងជនមានពិការភាព។

ដើម្បីដោះស្រាយ បញ្ហានៃការទទួលបានសេវាស្តារលទ្ធភាពពលកម្មក្នុងប្រទេសកម្ពុជាដែលនៅមានកម្រិត កិច្ចអន្តរាគមន៍មួយចំនួនត្រូវបានស្នើឡើងតាមរយៈយុទ្ធសាស្ត្រការពង្រឹងប្រព័ន្ធសុខាភិបាល ដែលទទួលស្គាល់ថា ជាវិធីសាស្ត្រដ៏ល្អបំផុតដើម្បីធានាថា សេវាស្តារលទ្ធភាពពលកម្មបានទៅដល់អ្នកដែលមានតម្រូវការទាំងអស់ តាមរយៈការធ្វើសមាហរណកម្មសេវាស្តារលទ្ធភាពពលកម្មនៅគ្រប់កម្រិតនៃប្រព័ន្ធសុខាភិបាល ដែលជាផ្នែកមួយនៃការគ្រប់ដណ្តប់សុខភាពជាសកល។ វិធីសាស្ត្រនេះរួមមាន៖ (១) ការស្តារលទ្ធភាពពលកម្ម គួរតែមាននៅកម្រិតថែទាំសុខភាពបឋម ដែលធ្វើឱ្យសេវាកាន់តែខិតទៅដល់សហគមន៍ ដែលចូលរួមកាត់បន្ថយនូវការចំណាយ និងពង្រឹងសមធម៌ ព្រមទាំងមានពេលវេលាសមស្របក្នុងការផ្តល់សេវា។ កត្តាទាំងនេះ ពាក់ព័ន្ធនឹងការផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកជំនាញថែទាំសុខាភិបាល ដើម្បីផ្តល់សេវាស្តារលទ្ធភាពពលកម្ម  ការរៀបចំ និងពង្រឹងប្រព័ន្ធបញ្ជូន និងធានាថាសេវាស្តារលទ្ធភាពពលកម្ម ត្រូវបានផ្តល់មូលនិធិគ្រប់គ្រាន់ និងអ្នកដែលត្រូវការអាចទទួលបានសេវា។ (២) ការស្តារលទ្ធភាពពលកម្ម មិនអាចពង្រីកតែឯងបានទេ ប្រព័ន្ធសុខាភិបាលត្រូវតែពង្រឹងបន្ថែម ដើម្បីការផ្តល់សេវាស្តារឱ្យកាន់តែប្រសើរឡើង រួមទាំងពង្រឹងផ្នែកផ្សេងៗ រួមមាន៖ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច ហិរញ្ញវត្ថុ ការផ្តល់សេវា កម្លាំងពលកម្ម បច្ចេកវិទ្យាជំនួយ និងព័ត៌មាន។

កិច្ចអន្តរាគមន៍ដែលបានស្នើឡើងមានគោលបំណង ពង្រឹងការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា នៅក្នុងខេត្តកំពង់ចាម។ ក្រៅពីការបន្តផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មខេត្តកំពង់ចាម សេវានៅក្នុងមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម ក៏ត្រូវតែពង្រឹងផងដែរ។

ACCESS 2
Sustainable quality services for all

Australian Aid

| |
|---|
| តាមរយៈកិច្ចអន្តរាគមន៍នេះ ភាពជាអ្នកដឹកនាំនៃមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម នឹងត្រូវបានណែនាំ គាំទ្រ និងផ្តល់ការបង្វឹក អំពីអភិបាលកិច្ចលើសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា រួមទាំងការយល់ដឹងអំពីសមាសធាតុសំខាន់ៗទាំងអស់នៃការផ្តល់សេវា។ មេរៀនសំខាន់ៗដែលទទួលបានរៀនពីកិច្ចអន្តរាគមន៍នេះ នឹងរៀបចំចងក្រងដើម្បីគាំទ្រដល់សេវាមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាក្នុងប្រទេសកម្ពុជានាពេលអនាគត ដែលជួយដល់ដំណើរការនៃការធ្វើសមាហរណកម្មនៃសេវាស្តារលទ្ធភាពពលកម្មនៅគ្រប់កម្រិតនៃប្រព័ន្ធសុខាភិបាល។ |
| **លទ្ធផលរំពឹងទុករបស់គម្រោង** |
| ១.ពង្រឹងសមត្ថភាពនៃភាពជាអ្នកដឹកនាំរបស់ថ្នាក់ដឹកនាំមន្ទីរពេទ្យទាក់ទងនឹងអភិបាលកិច្ចនៃសេវាស្តារលទ្ធភាពពលកម្ម។<br>២.ធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការ/ការសម្របសម្រួលរវាងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា ខេត្តកំពង់ចាមនិង និង មន្ទីរពេទ្យខេត្ត សម្រាប់ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា។<br>៣.រៀបចំ និងពង្រឹងប្រព័ន្ធបញ្ជូនបន្តដ៏រឹងមាំមួយសម្រាប់អ្នកផ្តល់សេវាដើម្បីបង្កើនការយល់ដឹង និងធានាបាននូវការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅក្នុងខេត្តកំពង់ចាម។ |
| **សកម្មភាពសំខាន់ៗ** |
| សកម្មភាព ១.១ ធ្វើការប៉ាន់ប្រមាណ និងរៀបចំផែនការយុទ្ធសាស្ត្រដើម្បីកំណត់អាទិភាព និងយុទ្ធសាស្ត្រផ្សេងៗទៀតសម្រាប់សេវាស្តារលទ្ធភាពពលកម្មនៅមន្ទីរពេទ្យខេត្តកំពង់ចាម។<br>សកម្មភាព ១.២ ការពង្រឹងសេវាព្យាបាលដោយចលនានៅមន្ទីរពេទ្យខេត្តកំពង់ចាម។<br>សកម្មភាព ១.៣ ផ្តល់វគ្គបណ្តុះបណ្តាលតាមផែនការដែលបានកំណត់ទុក រួមទាំងការផ្តល់វគ្គបណ្តុះបណ្តាលផ្នែកគ្រប់គ្រងជូនដល់ថ្នាក់ដឹកនាំនៃមន្ទីរពេទ្យខេត្តកំពង់ចាម។<br>សកម្មភាព ២.១ ពង្រឹងយន្តការបញ្ជូនបន្តឱ្យកាន់តែទូលំទូលាយរវាង មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ចាម និងមន្ទីរពេទ្យខេត្តសម្រាប់អ្នកដែលមានកម្សោយមុខងាររាងកាយ។<br>សកម្មភាព ២.២ បង្កើតនិងអនុវត្តយន្តការ ការវាយតម្លៃ និងផ្តល់សេវាអវយវៈសិប្បនិម្មិតនិងរណប នៅក្នុងមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម តាមរយៈបុគ្គលិកផ្នែកអវយវៈសិប្បនិម្មិតនិងរណបចល័ត នៃមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម និងមជ្ឈមណ្ឌលស្តារលទ្ធភាពពកម្មកាយសម្បទាខេត្តកំពង់ចាម។<br>សកម្មភាព ២.៣ ការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល (វេជ្ជបណ្ឌិត គិលានុបដ្ឋាកយិកា និងបុគ្គលិកផ្សេងទៀត) ស្តីពីការស្តារលទ្ធភាពពលកម្មឱ្យបានទាន់ពេលវេលា បន្ទាប់ពីការថែទាំវេជ្ជសាស្ត្រ។<br>សកម្មភាព៣.១ ការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល (វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិកផ្សេងទៀត) ស្តីពីការស្តារលទ្ធភាពពលកម្មឱ្យបានទាន់ពេលវេលា បន្ទាប់ពីការថែទាំវេជ្ជសាស្ត្រ។ |

សកម្មភាព៣.២ ការអនុវត្តសាកល្បងកញ្ចប់ស្តារលទ្ធភាពពលកម្មមូលដ្ឋាន (BRP) នៅក្នុងខេត្តកំពង់ចាម

សកម្មភាព៣.៣ បណ្តុះបណ្តាលអ្នកវិជ្ជាជីវៈសុខាភិបាល (មូលដ្ឋានសុខាភិបាល និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា) លើការផ្តល់សេវាសុខភាពប្រកបដោយបរិយាបន្នពិការភាព និងផាសុកវត្ត (ការបង្កលក្ខណៈងាយស្រួល)។

សកម្មភាព៣.៤ ការសាកល្បងការស្តារលទ្ធភាពពលកម្មពីចម្ងាយ ដើម្បីធានាបាននូវការថែទាំបន្តរវាងមន្ទីរពេទ្យបង្អែកស្រុក និងមន្ទីរពេទ្យខេត្ត។

**អ្នកទទួលផល**

- បុគ្គល និងគ្រួសារ៖ អ្នកដែលមានបញ្ហាផ្នែកមុខងារណាមួយនៃរាងកាយ រួមទាំងជនមានពិការភាព
- រចនាសម្ព័ន្ធនិង អ្នកផ្តល់សេវា៖ មន្ទីរពេទ្យខេត្តកំពង់ចាម មន្ទីរពេទ្យបង្អែកស្រុក ក្រសួងសុខាភិបាល មូលនិធិជនពិការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**អ្នកទទួលផលដោយប្រយោល**

- បុគ្គលនិងគ្រួសារ៖ សមាជិកគ្រួសារដែលមានបញ្ហាណាមួយនៃមុខងាររាងកាយ រួមទាំងជនមានពិការភាព។
- រចនាសម្ព័ន្ធនិងអ្នកផ្តល់សេវា៖ ប្រធាន អនុប្រធាន និងសមាជិកនៃមន្ទីរពេទ្យខេត្តកំពង់ចាម និងមន្ទីរពេទ្យបង្អែកស្រុក។ ក្រសួងសុខាភិបាល មូលនិធិជនពិការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**តំបន់គោលដៅ**

គម្រោងនឹងអនុវត្តនៅក្នុងខេត្តកំពង់ចាម ដោយមានការគាំទ្រសកម្មភាពផ្សេងៗទៅដល់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងមន្ទីរពេទ្យខេត្តកំពង់ចាម។ កាលពីឆ្នាំ ២០១៤ ខេត្តកំពង់ចាមត្រូវបានបំបែកចេញជា២ខេត្តគឺ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ហេតុនេះហើយទើប មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ចាម ត្រូវគ្រប់ដណ្តប់ទាំងពីរខេត្តនេះ។

**ដៃគូអនុវត្តគម្រោង**

- មន្ទីរពេទ្យខេត្តកំពង់ចាម
- មន្ទីរពេទ្យបង្អែកស្រុកព្រៃឈរ
- ក្រសួងសុខាភិបាល
- មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ចាម
- មូលនិធិជនពិការ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- សមាគមព្យាបាលដោយចលនាកម្ពុជា

| |
|---|
| ○ សមាគមអ្នកបច្ចេកទេសអវយវៈសិប្បនិម្មិតនិងរណបកម្ពុជា<br>○ អង្គការឆាយ<br>○ អង្គការជនពិការកម្ពុជា |
| **រយៈពេលអនុវត្តគម្រោង** |
| ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៤ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២៨ |
| **ព័ត៌មានទំនាក់ទំនង** |

| | |
|---|---|
| អង្គការ HI<br>លោក Rajib DAKUA ប្រធានគ្រប់គ្រងប្រចាំប្រទេស<br>ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២១៧ ៣០០<br>អ៊ីម៉ែល៖ r.dakua@hi.org | កម្មវិធី ACCESS 2<br>វេជ្ជបណ្ឌិត ជូ វិវឌ្ឍន៍<br>ប្រធានផ្នែកពិការភាព និងស្តារលទ្ធភាពពលកម្ម<br>ទូរស័ព្ទលេខ៖ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីម៉ែល៖ vivath.ch@access2cambodia.org |

គម្រោងនេះ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2)។

ខែតុលា  ឆ្នាំ២០២៤